នស/រកម/០៤០៥/០១៣

# ព្រះរាជក្រម

## យើង

## ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្ពូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/0៧0៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០០៤ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្មរ៉ែ និងថាមពល
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងមូលដ្ឋានស្តីពី កម្មវិធីសហប្រត្តិបត្តិការលើវិស័យឧស្សាហកម្មអាស៊ាន (AICO) ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ២ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៥ នាសម័យបជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងមូលដ្ឋានស្តីពីកម្មវិធីសហប្រតិបត្តិការលើវិស័យឧស្សាហកម្មអាស៊ាន (AICO)

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងមូលដ្ឋានស្តីពីកម្មវិធីសហប្រតិបត្តិការលើវិស័យឧស្សាហកម្មអាស៊ាន (AICO) ដែលធ្វើនៅសិង្ហបុរី នាថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ចករ
នរោត្តម សីហមុនី

នស/រកម.០៥០៤.១៥៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
ហត្ថលេខា
ស៊ុយ សែម

លេខ ១៤១ ច.ល
ដើម្បីចម្លងចែកចាយ
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០០៥
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
សុខ អាន
សុភាព (unclear)

3/3

# ពិធីសារធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងជាមូលដ្ឋានស្តីពីកម្មវិធីសហប្រតិបត្តិការលើវិស័យឧស្សាហកម្មអាស៊ាន (AICO)

រដ្ឋាភិបាលប្រទេសប្រ៊ុយណេ ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបូរី ព្រះរាជាណាចក្រថៃឡង់ និង សាធារណរដ្ឋសង្គមនិយមវៀតណាម សមាជិករបស់សមាគមជាតិអាស៊ីអាគ្នេយ៍( អាស៊ាន)

**ការរំលឹកដល់** កិច្ចព្រមព្រៀងជាមូលដ្ឋានស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យឧស្សាហកម្មអាស៊ាន AICO ចុះហត្ថលេខា ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៦ នៅប្រទេសសឹង្ហបូរី ដែលទីនេះហៅថា"កិច្ចព្រមព្រៀង" ដែលមានគោលបំណងផ្តល់នូវការចង្អុលបង្ហាញ និងក្របខ័ណ្ឌផ្លូវច្បាប់ ដែលក្នុងនោះផ្នែកឯកជនអាស៊ានអាចធ្វើកិច្ចសហប្រតិបត្តិការជាមួយគ្នានៅលើមូលដ្ឋានយោគយល់គ្នា និង មានផលប្រយោជន៍ទៅវិញទៅមកសំរាប់ប្រទេស ជាសមាជិកអាស៊ាន និង បង្កើននូវផលិតផលឧស្សាហកម្មសំរាប់តំបន់ទាំងមូល ។

**ការយល់ដឹង** ជាមួយនឹងការពេញចិត្តដែលកម្មវិធី AICO បានទទួលជោគជ័យតាមគោលដៅរបស់ខ្លួន ។

**ការកត់សំគាល់** ដូចគ្នាដែលមាត្រាទី១នៃពិធីសាធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងស្តីពីកម្មវិធី CEPT សំរាប់ AFTA ដើម្បីលុបបំបាត់ពន្ធនាំចូល បានចុះហត្ថលេខាថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៣ ធ្វើវិសោធនកម្មអត្រាពន្ធនៅទីបញ្ចប់នៃកម្មវិធី CEPT មកដល់ 0% ។

**ការរំលឹកដល់** ការសំរេចចិត្តនៃកិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាននៅ Genting Highland ប្រទេសម៉ាឡេស៊ី នៅខែ កក្កដា ឆ្នាំ២០០២ ដើម្បីធ្វើការរក្សានូវអ្វីដែលទាក់ទងដល់កម្មវិធី AICO ក្រោយ ២០០២ និងការប្រឹងប្រែងបញ្ចុះអត្រាពន្ធសំរាប់កម្មវិធី AICO ទៅដល់ 0% ។

**ការរំលឹកដល់** សេចក្តីសំរេចចិត្តរបស់កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៣៤ ដែលបានធ្វើឡើងនៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០២ នៅ Bandar Seri Begawan ប្រទេសប្រ៊ុយណេ ដើម្បីធ្វើការកែប្រែអត្រាពន្ធសមស្របទៅតាមប្រទេសសមាជិកដែលចូលរួមនៅក្នុងកម្មវិធី AICO ។

**ការទទួលស្គាល់** ការចាំបាច់ធ្វើអោយកិច្ចព្រមព្រៀងនៅតែមានភាពទាន់សម័យដើម្បីធ្វើការរក្សាវាអោយមាននិរន្តរភាពរហូតទៅក្រោយឆ្នាំ ២០០២ ។

**ការកត់សំគាល់** មាត្រា ១៣នៃកិច្ចព្រមព្រៀងអនុញ្ញាតអោយមានការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះ ។

**បានយល់ព្រមដូចខាងក្រោមនេះ:**

## មាត្រា១

មាត្រា១ (និយមនយ័) នៃកិច្ចព្រមព្រៀងនឹងត្រូវបានធ្វើការកែប្រែដោយជំនួសមាត្រា១(៦) ដូចខាងក្រោម:

"៦. " អត្រាអនុគ្រោះពន្ធ " មានន័យថា ជាអត្រាអនុគ្រោះពន្ធនាំមុខចុងបញ្ចប់នៃអត្រា CEPT ដែលកំនត់ដោយប្រទេសជាសមាជិកចូលរួមត្រឹម 0% ដូចដែលមានចែងនៅក្នុងពិធីសារវិសោធនកម្មនៃកិច្ចព្រមព្រៀងនេះ ហើយដែលបានចែងច្បាស់នៅក្នុងមាត្រា២(៤)នៃពិធីការវិសោធនកម្មនេះ និងមាត្រា ៤ នៃកិច្ចព្រមព្រៀង" ។

## មាត្រា២

មាត្រា២ (បទប្បញ្ញត្តិទូទៅ) នៃកិច្ចព្រមព្រៀងនឹងត្រូវបានធ្វើការកែប្រែដូចខាងក្រោម:

(ក) ដោយបញ្ចូលមាត្រាថ្មី ២(៤) បន្ទាប់ពីមាត្រាចាស់ ២(៣) ដូចខាងក្រោមនេះ:

" ៤. នៅក្នុងករណីដែលការរៀបចំកម្មវិធី AICO ត្រូវបានយល់ព្រមអនុវត្តចាប់ពីថ្ងៃទី ០១ ខែ មករាឆ្នាំ ២០០៣ អត្រាអនុគ្រោះពន្ធសំរាប់ប្រទេសជាសមាជិកនឹងត្រូវបានអនុវត្តនៅក្នុងអត្រាពន្ធកំនត់ដូចខាងក្រោម:

| | | |
|---|---|---|
| ក. ប្រទេសប្រ៊ុយណេ | - | 0% |
| ខ. ព្រះរាជាណាចក្រកម្ពុជា | - | 0% |
| គ. សាធារណរដ្ឋឥណ្ឌូនេស៊ី | - | 0% |
| ឃ. សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ | - | 0% |
| ង. ម៉ាឡេស៊ី | - | 0% |
| ច. សហភាពមីយ៉ាន់ម៉ា | - | 0-៥% |
| ឆ. សាធារណរដ្ឋហ្វីលីពីន | - | 0-១% |
| ជ. សាធារណរដ្ឋសឹង្ហបុរី | - | 0% |
| ឈ. ព្រះរាជាណាចក្រថៃឡង់ | - | 0-៣% |
| ញ. សាធារណរដ្ឋសង្គមនិយមវៀតណាម | - | 0-៥% |

ប្រទេសជាសមាជិកចូលរួម អាស្រ័យដោយមានការយោគយល់គ្នាទៅវិញទៅមក អាចបង្កើតកិច្ចព្រមព្រៀងទៅលើអត្រាអនុគ្រោះពន្ធរវាង ឬ ក្នុងចំណោមប្រទេសជាសមាជិកចូលរួមក្នុងកំរិតអត្រាពន្ធដូចមានចែងខាងលើនៃប្រទេសជាសមាជិកនិមួយៗ" ។

(ខ) ដោយដាក់បញ្ចូលមាត្រាថ្មី ២(៥)ដូចខាងក្រោមនេះ:

"៥. ប្រទេសជាសមាជិកអាស៊ានដូចមាននៅក្នុងមាត្រា ២ (៤) ដែលពួកគេស្ថិតនៅជាបណ្តោះអាសន្ន ពុំទាន់អនុវត្តអត្រាអនុគ្រោះពន្ធ0%នឹងត្រូវធ្វើការបញ្ចុះអត្រាអនុពន្ធរហូតដល់ 0%តាមកិច្ចព្រមព្រៀង AICO នៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៥លើកលែងតែសាធារណៈរដ្ឋវៀតណាមដែលនឹងត្រូវបញ្ចុះដល់ 0% នៅថ្ងៃទី០១ ខែ មករា ឆ្នាំ ២០០៦" ។

## មាត្រា៣

មាត្រា៥(សិទ្ធិ) នៃកិច្ចព្រមព្រៀងនឹងត្រូវបានកែប្រែដោយជំនួសមាត្រា៥(១)(ក) ដូចខាងក្រោម:

" ក. ផលិតផល AICO ដែលបានអនុញ្ញាតធ្វើពាណិជ្ជកម្មរវាងក្រុមហ៊ុនដែលចូលរួមនឹងត្រូវបានទទួលនូវការអនុគ្រោះពន្ធដូចដែលបានកំនត់ច្បាស់នៅក្នុងមាត្រា១(៦) និង មាត្រា២(៤) តាមដែលអាចធ្វើទៅបាន ។ នៅពេលណាដែលការកំណត់ការអនុគ្រោះពន្ធស្ថិតនៅក្នុងចន្លោះអត្រាពន្ធបានកំនត់ អត្រាពន្ធជាក់ស្តែងមួយត្រូវបានកំនត់ដោយប្រទេសជាសមាជិកចូលរួមនោះ ។ អត្រាអនុគ្រោះពន្ធត្រូវបានបញ្ចប់នៅ-ពេលណាដែលអត្រាពន្ធនៃផលិតផលទៅដល់អត្រាចុងបញ្ចប់នៃអត្រា CEPT ។

## មាត្រា៤

មាត្រា៧ (បែបបទពាក្យសុំ) នៃកិច្ចព្រមព្រៀងនឹងត្រូវបានកែប្រែជំនួសដោយមាត្រា៧(២)ដូចខាង ក្រោម:

" ២. ប្រទេសជាសមាជិកអាស៊ានក្នុងរយៈពេល៦០ថ្ងៃនៃការទទួលពាក្យសុំត្រូវជូនដំណឹងដល់លេខាធិការដ្ឋានអាស៊ាននូវ:

ក. ការសំរេចចិត្តរបស់ខ្លួននៅក្នុងការចូលរួមក្នុងកម្មវិធី AICO និង

ខ. នៅពេលសមស្រប អត្រាអនុគ្រោះពន្ធត្រូវបានអនុវត្តដូចដែលបានកំនត់នៅក្នុងមាត្រា១(៦) និង មាត្រា ២(៤) ។

ប្រសិនបើមានប្រទេសជាសមាជិកអាស៊ានណាពុំអាចធ្វើការកំណត់លើការសំរេចចិត្តលើអត្រាពន្ធនៅក្នុងអំឡុងពេលនេះយ៉ាងណាក៏ដោយ នឹង ត្រូវតែផ្តល់ការសំរេចចិត្តរបស់ខ្លួនលើការទទួលយល់ព្រម ឬ មិនយល់ព្រមនៃការរៀបចំបង្កើតកម្មវិធី AICO និង ទទួលយល់ព្រម ឬមិនយល់

ព្រមលើផលិតផល ជាផលិតផល AICO ។

## មាត្រា៥

មាត្រា១២ (ការលុបចោលបទបញ្ញត្តិផ្សេង១) នៃកិច្ចព្រមព្រៀង នឹង ត្រូវបានកែប្រែដោយធ្វើការជំនួសពាក្យ "បញ្ចប់" នៅក្នុងឃ្លាទីពីរនៃមាត្រា ១២(ឈ) ដោយពាក្យ " តាមការវិវត្តជាក់ស្តែង " ។

## មាត្រា៦

ពិធីសារនេះ នឹង ចូលជាធរមាននៅថ្ងៃដែលផ្តល់សច្ចាបន័ទទួលស្គាល់តំកល់ទុក ឬ ការទទួលស្គាល់ដោយភាគីហត្ថលេខីនៃរដ្ឋាភិបាលទាំងអស់ជាមួយនឹងអគ្គលេខាធិការអាស៊ាន ។

ពិធីសារនេះនឹងត្រូវបានតំកល់ទុកឯអគ្គលេខាធិការអាស៊ានដែលជាអ្នកមានភារកិច្ចចម្លងជូនទៅគ្រប់ប្រទេសជាសមាជិក ។

**នៅចំពោះមុខសាក្សី** ដែលបានចុះហត្ថលេខាខាងក្រោម ដោយមានការអនុញ្ញាតដោយរដ្ឋាភិបាលនៃប្រទេសនិមួយ១បានចុះហត្ថលេខាលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងជាមូលដ្ឋានលើវិស័យសហប្រតិបត្តិការឧស្សាហកម្មអាស៊ាន ។

ធ្វើនៅ ប្រទេសសឹង្ហបូរី ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០៤ ជាភាសាអង់គ្លេសតែមួយច្បាប់គត់ ។

ជ. រដ្ឋាភិបាលប្រទេសប្រ៊ុយណេ

Pehin Dato Abdul Rahman Taib
រដ្ឋមន្ត្រីឧស្សាហកម្ម និង ធនធាន ប្រុយណេដារូសាឡាម

ជ. រដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា

Cham Prasidh
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ជ. រដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូណេស៊ី

Rini M. S. Soevandi
រដ្ឋមន្ត្រីឧស្សាហកម្ម និង ពាណិជ្ជកម្ម

ជ. រដ្ឋាភិបាលប្រជាមានិតប្រជាធិបតេយ្យឡាវ

Soulivong Daravong
រដ្ឋមន្ត្រីពាណិជ្ជកម្ម

ជ. រដ្ឋាភិបាលម៉ាឡេស៊ី

Dato's Seri Rafidah Aziz
រដ្ឋមន្ត្រីពាណិជ្ជកម្មអន្តរជាតិ និង ឧស្សាហកម្ម

ជ. រដ្ឋាភិបាលសហភាពមីយ៉ាន់ម៉ា

U Tin Winn
រដ្ឋមន្ត្រីសហប្រតិបត្តិការសេដ្ឋកិច្ច

ជ. រដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន

Cesar A. V. Purisima
រដ្ឋលេខាធិការពាណិជ្ជកម្ម និង ឧស្សាហកម្ម

ជ. រដ្ឋាភិបាលសាធារណរដ្ឋសិង្ហបុរី

George Yong-Boon Yeo
រដ្ឋមន្ត្រីពាណិជ្ជកម្ម និង ឧស្សាហកម្ម

ជ. រដ្ឋាភិបាលព្រះរាជាណាចក្រថៃឡង់

Watana Muangsook
រដ្ឋមន្ត្រីពាណិជ្ជកម្ម

ជ. រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម

Truong Dinh Tuyen
រដ្ឋមន្ត្រីពាណិជ្ជកម្ម